# កម្ពុជាក្រោម

Kampuchea Krom

ព្រឹត្តិបត្របោះពុម្ពផ្សាយជារៀងរាល់ខែ ដោយសហព័ន្ធខ្មែរកម្ពុជាក្រោម – KKF's Monthly Newsletter

លេខ ០២ ឆ្នាំទី ០១ – ខែកុម្ភៈ គ.ស. ២០០៤ – ព.ស. ២៥៤៧ – Issue 02, February, 2004

## អត្ថបទខាងក្នុង

–សេចក្តីអំពាវនាវ ................................៣

–រឿង ១ ពាន់ ១ យប់ នៃគម្ពីរព្រះធម៌ សម្រាប់ខ្មែរក្រោម ................................៤

–សមណនិស្សិត និងនិស្សិតខ្មែរកម្ពុជា–ក្រោម គាំទ្រគោលនយោបាយសន្តិវិធី ....៦

–ជនភៀសខ្លួនខ្មែរកម្ពុជាក្រោម អបអរ–សាទរប្រជាជាតិ ម៉ុងតាញ៉ា ដែលបានចូលជាសមាជិក UNPO ..............................៦

–ពិធីបុណ្យរំឭកខួបឆ្នាំទី ៣ នៃអនិច្ចកម្ម របស់សម្តេចបវរសេដ្ឋាធិបតី ស៊ឺនសាន ..៧

–ឧត្តមគតិព្រះពុទ្ធឃោសាចារ្យ គឹម តុក ចើង ................................................៧

–សាកល្បងព្យាករណ៍អំពីជោគវាសនា នៃរបបអាណានិគមយួន ............................៩

–កំណាព្យ ទំនួញព្រះត្រពាំង .............១២

–ប្រលោមលោក វាសនាបុប្ផាខ្មែរក្រោម ..........................................................១៣

–រឿង ព្រះសមុទ្ទឃោស ....................១៥

# សេចក្តីប្រកាសព័ត៌មាន ដើមឆ្នាំ ២០០៤ របស់សហព័ន្ធខ្មែរកម្ពុជាក្រោមពិភពលោក

*ខ្មែរកម្ពុជាក្រោមនៅជុំវិញពិភពលោក ដែលភូមិកំណើតរបស់ពួកគេស្ថិតនៅក្រោមអាណានិគមនៃរបបយួនកុម្មុយនិស្ត បានមកជួបជុំគ្នានៅទីក្រុង សាន់ ហ្វូហ្សេ រដ្ឋកាលីហ្វ័រញ៉ា សហរដ្ឋអាមេរិក ដើម្បីទាមទារសិទ្ធិ និង យុត្តិធម៌របស់ខ្លួន ។*

ក្នុងកិច្ចប្រជុំប្រចាំឆ្នាំដែលចាត់ចែងដោយសហព័ន្ធខ្មែរកម្ពុជាក្រោម និងរៀបចំទទួលដោយសាខាសហព័ន្ធប្រចាំភាគខាងជើង នៃរដ្ឋកាលីហ្វ័រញ៉ា ស.រ.អា. ចាប់ពីថ្ងៃទី០២ ដល់ថ្ងៃទី០៤ ខែមករា ឆ្នាំ ២០០៤ នៅទីក្រុងសាន់ហ្វូហ្សេ មានអ្នកតំណាងខ្មែរកម្ពុជាក្រោមចំនួនជាង ១០០ នាក់ ក្នុងនោះមានព្រះសង្ឃ និង តំណាងនិស្សិតខ្មែរកម្ពុជាក្រោម ចំនួន ៣០នាក់ ដែលកំពុងសិក្សានៅតាមបណ្ដាសាកលវិទ្យាល័យ បានធ្វើដំណើរមកពី ប្រទេស អ៊ីតាលី បារាំង កម្ពុជា ឥណ្ឌា កាណាដា និង រដ្ឋចំនួន ២០ នៃសហរដ្ឋអាមេរិក ដើម្បីចូលរួមអង្គប្រជុំ ។ តាមសេចក្ដីប្រកាសព័ត៌មាន របស់សហព័ន្ធខ្មែរកម្ពុជាក្រោមបានឲ្យដឹងថា កិច្ចប្រជុំប្រចាំឆ្នាំដើម្បីដាក់ផែនការឆ្នាំ ២០០៤ ក្នុងបុព្វហេតុទាមទារសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង សម្រាប់ជនជាតិខ្មែរកម្ពុជាក្រោមដែលរស់នៅក្នុងប្រទេសវៀតណាមភាគខាងត្បូងបច្ចុប្បន្ន ។ ហើយអង្គប្រជុំបានសម្រេចជាឯកច្ឆន្ទដូចតទៅ ៖



*តំណាងនិស្សិតខ្មែរកម្ពុជាក្រោមជុំវិញពិភពលោក ដែលមកជួបជុំនៅ សាន់ហ្វូហ្សេ*

១–សុំប្ដឹងជាអន្តរជាតិ ចំពោះអំពើឧក្រិដ្ឋកម្មសម្លាប់រង្គាល ប្រឆាំងខ្មែរកម្ពុជាក្រោមដោយរដ្ឋាភិបាលកុម្មុយនិស្តយួន នៅក្នុងអំឡុងពេលខាងក្រោមនេះ ៖

ក–ជំនាន់សង្គ្រាមលោកលើកទី ២ ឆ្នាំ ១៩៤៥ ខ្មែរក្រោមរាប់ម៉ឺននាក់ បានត្រូវគេដុតទាំងរស់ ។

ខ-ក្នុងឆ្នាំ ១៩៧៦ ដល់ឆ្នាំ ១៩៧៩ ខ្មែរក្រោមរាប់ម៉ឺននាក់ បានត្រូវប្រហារជីវិតនៅតាមបណ្តាខេត្ត នៃដែនដីសណ្តទន្លេមេគង្គ ។

គ-ឆ្នាំ ១៩៧៨ មានការបង្ខំជន្លៀសមនុស្សចេញ និងមានអំពើលួចប្លន់ទ្រព្យសម្បត្តិខ្មែរ ព្រមទាំងវត្តអារាមនៅក្នុងខេត្តមាត់ជ្រូកទាំងមូល ។

ឃ-ឆ្នាំ ១៩៨៤ ដល់ឆ្នាំ ១៩៩០ ពេលព្រះតេជគុណ គឹម តុកចើង និងព្រះសង្ឃជាច្រើនអង្គ រួមទាំងប្រជាពលរដ្ឋខ្មែរក្រោម ជាច្រើននាក់ទៀតត្រូវគេធ្វើឃាត និងធ្វើទុក្ខបុកម្នេញ នៅក្នុងខេត្តព្រះត្រពាំង និង ខេត្តឡាំងហោ ។


ទិដ្ឋភាពនៃអង្គប្រជុំ នៅ សាន់ហូហ្សេ

ង-ការធ្វើឃាតព្រះតេជគុណ លឹម យៃន ក្នុងខែកក្កដា ឆ្នាំ ២០០២ នៅវត្តទឹកល្អក់ ស្រុកវីធ្វី ខេត្ត ព្រៃកឫស្សី ។

២-សុំឲ្យសាធារណរដ្ឋ សង្គមនិយមវៀតណាម អនុវត្តនូវសច្ចានុម័តរបស់មហាសន្និបាទ អង្គការសហប្រជាជាតិ លេខ ៥៥/១៤៦ ថ្ងៃទី ០៨ ធ្នូ ឆ្នាំ ២០០០ ដើម្បីបញ្ចប់អាណានិគម ទៅលើទឹកដីកម្ពុជាក្រោម ជាមាតុភូមិរបស់ប្រជាពលរដ្ឋខ្មែរកម្ពុជាក្រោម ដែលមានទំហំ ៦៨.៦០០ គីឡូម៉ែត្រក្រឡា ស្ថិតនៅភាគខាងត្បូងបំផុតនៃប្រទេសវៀតណាមបច្ចុប្បន្ន ។

៣-សុំឲ្យសាធារណរដ្ឋ សង្គមនិយមវៀតណាម ដាក់ទឹកដីកម្ពុជាក្រោម ឲ្យស្ថិតនៅក្រោមការគ្រប់គ្រងរបស់អង្គការសហប្រជាជាតិតាមធម្មនុញ្ញ នៃអង្គការសហប្រជាជាតិ ជំពូកទី ១១ ១២ និង ១៣ ដើម្បីបង្កើតឡើងនូវបរិយាកាស នយោបាយសេរី និងយុត្តិធម៌ អនុញ្ញាតិឲ្យខ្មែរកម្ពុជាក្រោម អនុវត្តនូវសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង ។

៤-សុំដល់សហគមន៍អន្តរជាតិ និង អ្នកវិនិយោគនៅវៀតណាម មេត្តាយល់ដឹងអំពីកាយវិការរបស់រដ្ឋាភិបាលវៀតណាម ចំពោះខ្មែរក្រោមដែលជាអំពើឡប់ឡែយ៉ាងពិតប្រាកដណាស់ ដើម្បីទទួលលុយជំនួយអន្តរជាតិ ហើយ នាំសហគមន៍អន្តរជាតិធ្វើមិនដឹង មិនឮ ចំពោះបញ្ហាដូចតទៅនេះ ៖ ក-អំពើឧក្រិដ្ឋកម្មសម្លាប់រង្គាល របស់រដ្ឋាភិបាលប្រឆាំងខ្មែរក្រោមកន្លងមក ។ ខ-បន្តការជិះជាន់ សង្កត់សង្កិន និង អំពើរំលោភសិទ្ធិខ្មែរក្រោម។ គ-ការទាមទាសិទ្ធិ សម្រេចវាសនាខ្លួនដោយខ្លួនឯងរបស់ខ្មែរកម្ពុជាក្រោម ។ កាយវិការសេរីៗ ទាំងអស់នេះពុំមែនជាដំណោះស្រាយយូរអង្វែង សម្រាប់សន្តិភាព និងស្ថិរភាពនៅក្នុងប្រទេសវៀតណាម និងនៅក្នុងតំបន់ទេ ។

ក្នុងសារលិខិតមួយ ផ្ញើទៅកាន់យុវជនខ្មែរកម្ពុជាក្រោមជុំវិញពិភពលោក លោក ថៅ សេរី បានវាយតម្លៃថាផែនការណ៍ទាំង ៤ នេះ មិនត្រឹមតែបានបំភ្លឺការចេះដឹងដល់ក្រុមយុវជនតែប៉ុណ្ណោះទេ តែថែមទាំងជួយជំរុញឲ្យក្រុមយុវជនបានសម្រេចគោលបំណង និងចក្ខុវិស័យនាអនាគតពុំខានឡើយ ។ លោកបណ្ឌិត Cooper ដែលជាសាស្ត្រាចារ្យច្បាប់ ក៏បានចូលរួមពន្យល់អំពីសិទ្ធិមនុស្សដល់ក្រុមយុវជនខ្មែរកម្ពុជាក្រោមក្នុងអង្គប្រជុំ ។ ហើយការពន្យល់របស់លោកបណ្ឌិតរូបនេះ គឺទាក់ទងទៅដល់ស្ថានភាពបច្ចុប្បន្នរបស់ជនរួមជាតិខ្មែរកម្ពុជាក្រោម ៕

VOKK


និពន្ធនាយក ៖ **ថាច់ ឌុ៉ក ថាច់**

អ្នកនិពន្ធ ៖ **ទ្រឹង ភូនាន់, តាំង សារៈ, ថាច់ សុមេធ, លី ឈួន, ឡឹម សុជាតា, ថាច់ សូរិយា**

ការិយាល័យទំនាក់ទំនង និងចែកផ្សាយ ៖

Worcester, MA 01613, USA

P.O. Box 2569, Tel: (508) 922-4834

E-mail: kkfnewsletter@khmerkrom.net

kkfnewsletter@yahoo.com

ការបោះពុម្ពបែប PDF មាននៅក្នុងគេហទំព័រ www.khmerkrom.net

# សេចក្តីអំពាវនាវ

*របស់ លោក ថាច់ ង៉ុក ថាច់ អនុប្រធានប្រតិបត្តិសហព័ន្ធខ្មែរកម្ពុជាក្រោមពិភពលោក ប្រចាំប្រទេសកាណាដា ចុះថ្ងៃទី ១៦ មករា ២០០៤*

## សូមមេត្តាបញ្ចប់រឿងអាស្រូវចំពោះកញ្ញា ម៉េង កែវ ពេជ្ជតា

ដោយយល់ឃើញថាបញ្ហា កញ្ញា ម៉េង កែវពេជ្ជតា បានធ្វើឲ្យសាធារណជន មានការភ័ន្តច្រឡំនាំមកនូវពាក្យចចាមអារ៉ាម ក្លាយជារឿងអាស្រូវកើតឡើងគួរឲ្យសោក–ស្តាយបំផុត ។ ការពិត កញ្ញា ម៉េង កែវពេជ្ជតា បានបង្ហាញ នូវភាពស្មោះត្រង់ បង្ហាញនូវការខ្លាចគ្រោះថ្នាក់លើរូបនាងដែលជាសិល្បការិនីមួយរូប ។ ដូចលោកអ្នកឃើញស្រាប់ សិល្បករខ្មែរយើងទទួលរងគ្រោះជាហូរហែតួយ៉ាងនាងកញ្ញា ទូច ស៊ុននិច (ទូច ស្រីនិច) ។ ទោះបីនាងមិនព្រម សម្តែងនៅលើវេទិការ ដែលមានបដាសហ–ព័ន្ធខ្មែរកម្ពុជាក្រោមក៏ដោយ ក្រោយពេលដែលបានប្រាប់នូវមូលហេតុហើយនោះ ខ្ញុំយល់ថា គួរតែស្តាប់គ្នាបាន គួរតែយល់នូវទឹកចិត្តរបស់នាង ។ នាងមិនបានបដិសេធថាមិនសម្តែងនោះ គឺបង្ហាញថា នាងគាំទ្រទៅហើយ ម្យ៉ាងទៀត នាងបានបំពេញភារកិច្ចជាអ្នកសិល្បៈ ជាកូនខ្មែរស្រឡាញ់សិល្បៈ តើមានអ្វីគួរឲ្យរិះគន់ ឬថានាងមិនចូលចិត្ត ឬប្រកាន់នោះ ។ ការពិត គឺមកពីមូលហេតុពុំមានការអនុគ្រោះទៅតាមកាលៈទេសៈ និង ពេលវេលា ។ ពាក្យចាស់លោកថា «*គិតប្រយោជន៍ឯង ឲ្យក្រែងប្រយោជន៍គេ*» ។ ខ្មែរយើងជាអ្នកកាន់ព្រះពុទ្ធសាសនា យកធម៌មេត្តា អនុគ្រោះ និង ខន្តីមកដោះស្រាយ កុំយកនូវសេចក្តីមានៈមកជាត្រីមុខ ។

ជាតិខ្មែរយើងរងគ្រោះច្រើនណាស់ រាប់សិបឆ្នាំមិនថាខ្មែរនៅទីណាទេ បើជាតិគេមើលងាយយើងហើយ ហេតុម្តេចក៏យើងខំប្រឹងមើលងាយខ្លួនឯងទៀត ? ។

ក្នុងនាមខ្ញុំបាទផ្ទាល់ ដែលជាកូនខ្មែរមួយរូបស្រឡាញ់ជាតិ ស្រឡាញ់សិល្បៈ ខ្ញុំសូមធ្វើសេចក្តីអំពាវនាវ ដល់ជនរួមឈាមខ្មែរទាំងអស់ ជាពិសេសខ្មែរកម្ពុជាក្រោម សូមមេត្តាធ្វើការពិចារណាបញ្ហានេះឡើងវិញ ។ រដ្ឋាភិបាលយួន បំផ្លាញវប្បធម៌ជាតិយើងយ៉ាងឈឺចាប់បំផុត សិល្បៈយើងបានត្រូវគេកាឡៃពីធាតុដើម ។ ដូច្នេះឫសគល់សិល្បៈខ្មែរ មាននៅតែព្រះរាជាណាចក្រកម្ពុជាប៉ុណ្ណោះ ។ បើអ្នកសិល្បៈខ្មែរនៅទីនោះមានគ្រោះថ្នាក់ជាបន្តបន្ទាប់មានការភ័យខ្លាច ហេតុអ្វីក៏មិននាំគ្នាជួយការពារជួយរកមធ្យោបាយដោះស្រាយ បែរជានាំគ្នាបំភ័យថែមទៅវិញ ។ មើលងាយ មើលថោក វាខុសគ្នាស្រឡះពីការភ័យខ្លាច ខុសគ្នានឹងអ្វីដែលរដ្ឋាភិបាលយួន ដែលមានផែនការបំផ្លាញវប្បធម៌ និង ខុសគ្នាស្រឡះពីកាយវិការស្មោះត្រង់របស់កញ្ញា ម៉េង កែវ ពេជ្ជតា ។ តើយើងអាចបិទភ្នែកបានទេ បើសិល្បករខ្មែរមានគ្រោះថ្នាក់ពីមួយទៅមួយនោះ ? ។

ទើបតែសម័យនេះទេ ដែលសិល្បករខ្មែរមានភ័ព្វវាសនាបានមកសម្តែងនៅប្រទេសក្រៅ ។ ជាតិគេលើកតម្កើងសិល្បៈណាស់ ព្រោះសិល្បៈជាយឿនវប្បធម៌ជាតិ។ សូមមេត្តាកុំធ្វើអ្វី ដែលផ្តល់ប្រយោជន៍ដល់គេឲ្យសោះ យើងមានឈាមជ័រតែមួយ និយាយភាសាតែមួយ វប្បធម៌តែមួយ មានអ្វីដែលលំបាកនិងស្តាប់គ្នានោះ ។

យើងខ្ញុំសង្ឃឹមថា រឿងអាស្រូវឥតប្រយោជន៍នឹងបញ្ចប់ត្រឹមនេះ សូមមេត្តារក្សាវប្បធម៌ខ្មែរទាំងអស់គ្នា សូមរក្សាការអប់រំគ្នាជាខ្មែរអ្នកមានពូជអម្បូរ ជាអ្នកគោរព និង កាន់ព្រះពុទ្ធសាសនា ។

*សូមអរគុណ*

# រឿង ១ ពាន់ ១ យប់ នៃគម្ពីរព្រះធម៌ សម្រាប់ខ្មែរកម្ពុជាក្រោម

សេចក្តីផ្តើមនៃរឿង បានចាប់ផ្តើមកាលពីថ្ងៃ ទី ១២ វិច្ឆិកា ១៩៩៦ ដែលតម្រួតអាណានិគមយួននៅច្រកព្រំដែនស្វាយរៀង-តៃនិញ (រោងដំរី) បានចាប់យកព្រះត្រៃបិដកមួយចប់របស់ពុទ្ធបរិស័ទខ្មែរ ដែលមានព្រះភិក្ខុ នេត្រ ដារ៉ូ ជាសាមីដើមទាន នៃអង្គកឋិនទានដង្ហែរទៅកាន់វត្តមុន្នីរង្សីស្រុកកំពង់ស្ពាន ខេត្តព្រះត្រពាំង។ តាមថេរដីការបស់ព្រះភិក្ខុអង្គនេះ បានឲ្យដឹងថា មុននឹងដង្ហែរទៅ ព្រះអង្គបានទៅសុំទិដ្ឋាការពីស្ថានទូតយួនប្រចាំនៅព្រះរាជាណាចក្រកម្ពុជាដែរ តែគេឆ្លើយថា គេអាចចេញទិដ្ឋាការឲ្យមនុស្សបាន ឯរឿងព្រះត្រៃបិដកនេះ គេមិនអាចចេញទិដ្ឋាការឲ្យបានទេ តែមិនជាបញ្ហាអ្វីទេ ព្រះអង្គនិមន្តនាំទៅចុះ ។ ព្រះភិក្ខុ នេត្រ ដារ៉ូ មិនអស់ចម្ងល់ក៏និមន្តទៅសួរនាំសុំច្បាប់ពីលោក ហៀង វណ្ណារ័ត្ន ជារដ្ឋមន្ត្រីក្រសួងធម្មការ នៃព្រះរាជាណាចក្រកម្ពុជា ។ លោក ហៀង វណ្ណារត្ន ឆ្លើយថា ប្រទេសយើងទាំងពីរពុំទាន់មានទំនាក់ទំនងវិស័យវប្បធម៌នូវឡើយ ហេតុនេះលោកមិនអាចជួយអ្វីព្រះអង្គបានទេ ។

ព្រះភិក្ខុ នេត្រ ដារ៉ូ មានថេរដីកាបន្តថា បន្ទាប់ពីចាប់យកព្រះត្រៃបិដករបស់ព្រះអង្គហើយ ព្រះអង្គបានប្តឹងដល់អគ្គកុងស៊ុលព្រះរាជាណាចក្រកម្ពុជា ប្រចាំទីក្រុងព្រៃនគរ ឲ្យជួយធ្វើអន្តរាគមន៍ដែរ ។ ឯខាងវៀតណាមគេឆ្លើយតបថាឲ្យព្រះអង្គត្រឡប់ទៅកម្ពុជាសិនចុះ ចាំក្រសួងសិក្សាធិការគេពិនិត្យសិន បើប្រសិនជាគម្ពីរព្រះធម៌មែន គេនឹងសងមកព្រះអង្គវិញ ។ យួនចេះតែឆ្លើយសិនរហូតមកដល់ឆ្នាំ ២០០១ ព្រះអង្គបានផ្ទេរការទំនាក់ទំនង



ទិដ្ឋភាពសាលារៀនខ្មែរនៅកម្ពុជាក្រោម រូបថត ៖ មីលិញ



ទាមទារព្រះត្រៃបិដកមកវិញនេះឲ្យដល់ភិក្ខុ **សាង ធឿង** ជាលេខាធិការ ព្រះតេជគុណ **ត្រឹង យន់** ជាព្រះមេគណខ្មែរក្រោម ប្រចាំខេត្តព្រះត្រពាំង ។

ព្រះភិក្ខុ **សាង ធឿង** បាននាំយកទៅជាមួយនូវលិខិតអន្តរាគមន៍លេខ 90CERC/2001 របស់អគ្គកុង-ស៊ុល នៃព្រះរាជាណាចក្រកម្ពុជាប្រចាំទីក្រុងព្រៃនគរ ចុះថ្ងៃទី ១២ ខែវិច្ឆិកា ២០០១ ចុះហត្ថលេខាដោយ ឯកឧត្តម **ហែម សាអែម** ដើម្បីសុំយកព្រះត្រៃបិដកមកវិញ តែភាគីយួនឆ្លើយថា សំណុំរឿងនេះទុកចោលយូរណាស់មកហើយ ហេតុនេះឯកសារដែលទាក់ទិននឹងរឿងនេះ ព្រមទាំងព្រះត្រៃបិដកនោះក៏បាត់បង់អស់ទៅហើយដែរ ។

ព្រះភិក្ខុ **នេត្រ ដារ៉ូ** មានថេរដីកាបន្ថែមថា ៖ តាមកំណត់ហេតុរបស់យួន លេខ 127BB–CHR1996 និងសេចក្តីសម្រេចលេខ 90/CD–HCR1996 គេចោទព្រះអង្គថា *"នាំយកមកនូវវប្បធម៌អាក្រក់ មកសាបព្រោះក្នុងប្រទេសវៀតណាម"* តែការពិត គឺព្រះត្រៃបិដកសុទ្ធសាធ។

ហើយថ្មីៗនេះ តាមព័ត៌មានពីព្រះភិក្ខុ **លី ចាន់នេន** មានព្រះជន្ម ៣៦ ព្រះវស្សា មានដើមកំណើតនៅកម្ពុជាក្រោម សព្វថ្ងៃគង់នៅវត្តមហាមន្ត្រី រាជធានីភ្នំពេញ។ ព្រះអង្គមានថេរដីកាថា កាលពីថ្ងៃទី ១៨ វិច្ឆិកា ២០០៣ ព្រះអង្គបាននិមន្តទៅស្រុកកំណើត ឯវត្តពុតធ្លេថ្មី ស្រុកពុតធ្លេ ខេត្តពលលាវ ត្រូវធ្វើដំណើរតាមច្រកព្រំដែនភ្នំដិនក្របៅ (ទិញបៀង) ជាព្រំប្រទល់នៃខេត្តតាកែវ និងខេត្តមាត់ជ្រូក (កម្ពុជាក្រោម) ក្នុងពេលឆ្លងកាត់ព្រំដែននេះ ឆ្មាំព្រំដែនយួន បានគំរាមគំហែង ជេរស្តី ឆែកឆេរថង់យាម

របស់ព្រះអង្គ ហើយរឹបអូសយកសៀវភៅអស់ ៣ ក្បាល រួមមានសៀវភៅណែនាំអំពីកិច្ចការបោះឆ្នោត ដែលចង-ក្រង និងបោះពុម្ពដោយមូលនិធិសម្តេច សឺន សាន ចំនួន ២ ក្បាល និងសៀវភៅព្រះធម៌កិច្ចវត្តព្រឹកល្ងាចដែលចង-ក្រង និងបោះពុម្ពដោយព្រះសង្ឃវត្តជង្រុក ១ ក្បាល ។

ឆ្មាំព្រំដែនយួន ដែលរឹបអូសយកសៀវភៅព្រះអង្គនោះរួមមាន ៖ ១-ង្វៀង វ៉ាំង ទឺ (Nguyen Van Tu) មេប៉ុស្តិ៍ ២-ង្វៀង ហ្វា ផុង (Nguyen Hoa Phong) ជាសមត្ថកិច្ចត្រួតពិនិត្យ ឆែកឆេរ សួរចម្លើយ និង ៣-ថៅ អង ជាសមត្ថកិច្ចកំណត់ហេតុ ។

ពួកគេបានធ្វើកំណត់ហេតុបំភ្លៃ ដោយសរសេរថា ទីមួយព្រះអង្គបានប្រគល់សម្ភារៈគឺសៀវភៅទាំងនេះ តាមសម្រួលដល់ពួកគេ តែតាមថេរដិការបស់ព្រះអង្គគឺពួកគេរឹបអូសយកទេ ។ ទីពីរ សៀវភៅស្តីអំពីកិច្ចការណែនាំបោះឆ្នោតរបស់មូលនិធិសម្តេច សឺន សាន គេសរសេរក្នុងកំណត់ហេតុថាជាសៀវភៅផ្សព្វផ្សាយ ពីគោលនយោ-បាយរបស់គណបក្ស សឺន សាន ទៅវិញ ។

លុះទៅដល់ស្រុកកំណើត ព្រះភិក្ខុ **លី ចាន់នេន** ត្រូវបានអាជ្ញាធរស្រុកពុតថ្លេ និង អាជ្ញាធរខេត្តពលលាវ និមន្តទៅសួរចម្លើយ អស់ពីស្តីបន្ទោស គំរាមកំហែង ដល់លួងលោម សុំឲ្យព្រះអង្គជួយធ្វើចារកម្មឲ្យគេ ។ គឺយួនឲ្យរាយការណ៍អំពីសកម្មភាពរបស់ខ្មែរក្រោមនៅក្រៅស្រុក តើកំពុង និងបម្រុងធ្វើអ្វីខ្លះ បើព្រះអង្គមិនជួយធ្វើចារកម្មឲ្យគេ ព្រះអង្គនឹងមិនបានសុខឡើយ ។ លុះត្រឡប់មកដល់ភ្នំពេញវិញ ព្រះអង្គបានប្តឹងរឿងនេះ ដល់ស្ថាន-ទូតយួនប្រចាំរាជធានីភ្នំពេញ យួនឆ្លើយថាគេមិនបានដឹងទេរឿងហ្នឹង ហើយនេះជាភារកិច្ចរបស់ឆ្មាំព្រំដែន គេសូមឲ្យព្រះអង្គទិញសៀវភៅថ្មីទៀតចុះ ។

រីឯគណៈកម្មការសម្របសម្រួល ខ្មែរកម្ពុជាក្រោម ដែលដឹកនាំដោយលោក **គឹម វណ្ណឆេង** នៅព្រះរាជាណា-ចក្រកម្ពុជា ក៏ច្រើនលើកច្រើនសា ទទូចសុំដង្ហែព្រះ-ត្រៃបិដក ពីរាជធានីភ្នំពេញ ទៅកាន់សាលាគណចំនួន ៤ នៅកម្ពុជាក្រោម កាលពីចុងឆ្នាំ ២០០៣ នេះ ។ ស្ថានទូតយួននៅភ្នំពេញ ពុំបានអនុញ្ញាតិឲ្យប្រតិភូរបស់លោក **គឹម វណ្ណឆេង** ចូលជួប ដើម្បីពិភាក្សាកិច្ចការដង្ហែព្រះត្រៃបិដកទេ ថែមទាំងជម្រាបសារព័ត៌មាននៅទីនេះថា គេមិនខ្វល់និងក្រុមខ្មែរក្រោម ។ ដោយមិនសុខចិត្តចំពោះអាកប្ប-កិរិយាប្រកាន់ពូជសាសន៍បែបនេះ លោក **គឹម វណ្ណឆេង** ក៏រៀបចំធ្វើសន្និសីទកាសែតកាលពីថ្ងៃទី ៤ វិច្ឆិកា ឆ្នាំ ២០០៣ ជម្រាបសារព័ត៌មាន និង សាធារណជនអំពីបំណងប្រាថ្នារបស់លោក និងខ្មែរក្រោមនៅទីនោះ ។ ក្រោយមក មានការអន្តរាគមន៍ពីអ្នកតំណាងរាស្ត្រ **កែវ រ៉េមី** ភាគីយួន បានឆ្លើយក្នុងសារលិខិតមួយតាមរយៈក្រសួងការបរទេសខ្មែរ ទៅកាន់លោក **កែវ រ៉េមី** ចុះថ្ងៃ ទី ០៦ មករា ២០០៤ ពុំបានអនុញ្ញាតឲ្យធ្វើការដង្ហែទេ ។ ដូច្នេះ លោក **គឹម វណ្ណឆេង** និង គណៈកម្មាការសម្របសម្រួលខ្មែរកម្ពុជាក្រោម នៅតែតវ៉ាបន្តទៅទៀត ដោយហេតុថាភាគីយួន ពុំបានតបនៅអ្វីដែលគាត់ទាមទារនោះទេ ព្រមទាំងពុំបានអើពើ ដល់ទំនៀមទម្លាប់ព្រះពុទ្ធសាសនាខ្មែរទៀតផងដែរ ។

រឿងគម្ពីរព្រះធម៌ ដង្ហែទៅកាន់កម្ពុជាក្រោមនេះ ប្រហែលជានៅអូសបន្លាយវែងឆ្ងាយទៀត ប៉ុន្តែយ៉ាងណាក៏ដោយ យើងខ្ញុំសង្ឃឹមថាទីបំផុតសច្ចធម៌ត្រូវតែឈ្នះ ទើបសង្គមមនុស្សលោកមានការរីកចម្រើន និងស្ថិរភាពនយោបាយនៅវៀតណាម ក៏ដូចជាក្នុងតំបន់ ជាស្ថិរភាពយូរអង្វែង ៕

***លី ឈួន***



*រូបថតព្រះ ភិក្ខុ លី ចាន់នេន ថតកាលពីខែ មករា ២០០៤ នៅភ្នំពេញ*

# សមណនិស្សិត និងនិស្សិតខ្មែរកម្ពុជាក្រោម គាំទ្រគោលនយោបាយសន្តិវិធី

លោក សឺន ទូន ប្រធានប្រតិបត្តិសហព័ន្ធខ្មែរកម្ពុជាក្រោម ទទួលបានលិខិតគាំទ្រមួយ ចុះថ្ងៃទី ០១ ខែមករា ឆ្នាំ ២០០៤ ពីសំណាក់ព្រះភិក្ខុ យឿង វណ្ណា ព្រះ–ប្រធានសម្ព័ន្ធសមណនិស្សិត និងនិស្សិតខ្មែរកម្ពុជាក្រោម នៅរាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ។ សម្ព័ន្ធសមណនិស្សិត និងនិស្សិតខ្មែរកម្ពុជាក្រោម ជាអង្គការមួយ មានសមាជិកចំនួន ១១០ ជាសមណនិស្សិត និងនិស្សិតមានដើមកំណើតជាខ្មែរកម្ពុជាក្រោម សព្វថ្ងៃកំពុងសិក្សានៅក្នុងសាកលវិទ្យាល័យនានា នៅព្រះរាជាណា–ចក្រកម្ពុជា ។

ក្នុងលិខិតផ្ញើជូនសហព័ន្ធខ្មែរកម្ពុជាក្រោម ដោយព្រះភិក្ខុ យឿង វណ្ណា ព្រះអង្គសូមបួងសួងឲ្យថ្នាក់ដឹកនាំ និងសមាជិក សមាជិកាសហព័ន្ធ ឲ្យជួបតែសេចក្តីសុខសេចក្តីចម្រើន និងទទួលបានជោគជ័យជាបន្តបន្ទាប់ ។ ជាពិសេស ព្រះអង្គបានសម្តែងនូវការគាំទ្រដល់សកម្មភាពអហឹង្សារបស់សហព័ន្ធ ក្នុងបុព្វហេតុស្វែងរកយុត្តិធម៌ សិទ្ធិ និងសេរីភាពសម្រាប់ជនរួមឈាម និងព្រះសង្ឃ ដែលកំពុងរស់នៅលើទឹកដីកម្ពុជាក្រោម ដោយពុំមានសិទ្ធិសេរីភាព និងយុត្តិធម៌ តាមធម្មនុញ្ញ និងកតិការសញ្ញានានានៃអង្គការសហប្រជាជាតិ ។

តាងនាមឲ្យសហព័ន្ធខ្មែរកម្ពុជាក្រោម ក្នុងលិខិតប្រគេនព្រះភិក្ខុប្រធាន និងសមាជិក សមាជិកាទាំងអស់នៃសម្ព័ន្ធសមណនិស្សិត និងនិស្សិតខ្មែរកម្ពុជាក្រោម ចុះថ្ងៃទី ០៩ ខែមករា ឆ្នាំ ២០០៤ លោកប្រធានប្រតិបត្តិសហ–ព័ន្ធខ្មែរកម្ពុជាក្រោម បានសម្តែងការអបអរសាទរ និងសេចក្តីរីករាយជាអតិបរិមា សូមទទួលយកសព្ទសារធុការពរ និងសេចក្តីគាំទ្រ របស់សម្ព័ន្ធសមណនិស្សិត និងនិស្សិតខ្មែរកម្ពុជាក្រោម នៅព្រះរាជាណាចក្រកម្ពុជា ។ លោកបានស្នើឲ្យមានយន្តការទំនាក់ទំនង និងសហការដ៏មានប្រសិទ្ធិភាព រវាងសម្ព័ន្ធសមណនិស្សិត និងនិស្សិតខ្មែរកម្ពុជាក្រោម ជាមួយសហព័ន្ធខ្មែរកម្ពុជាក្រោមពិភពលោក ព្រមទាំងសហគមន៍ព្រះសង្ឃខ្មែរកម្ពុជាក្រោមពិភពលោក ដើម្បីជម្រុញឲ្យការតស៊ូដោយសន្តិវិធីតាមគោលការណ៍របស់សហព័ន្ធខ្មែរកម្ពុជាក្រោម ឲ្យទទួលបានជោគជ័យជាលំដាប់លើឆាកអន្តរជាតិ ។ ប្រយោជន៍នាំមកឲ្យបានទាន់ពេលវេលា នូវសេចក្តីសង្ឃឹម និងសិទ្ធិសេរីភាពដ៏ពិតប្រាកដសម្រាប់ជនរួមឈាម និងព្រះសង្ឃដែលកំពុងរស់នៅលើទឹកដីកម្ពុជាក្រោម មាតុភូមិជាទីស្នេហារបស់យើង ៕

*ឡឹម សុជាតា*

# ជនភៀសខ្លួនខ្មែរកម្ពុជាក្រោម អបអរសាទរប្រជាជាតិម៉ង់តាញ៉ា ដែលបានចូលជាសមាជិក UNPO

ពេលទទួលបានព័ត៌មានពី ព្រឹត្តិបត្រកម្ពុជាក្រោម លេខ ០១ ដែលមានអត្ថបទស្តីអំពីការចូលជាសមាជិក UNPO របស់ប្រជាជាតិ ម៉ង់តាញ៉ា នៅភូមិភាគកណ្តាលនៃប្រទេសវៀតណាមបច្ចុប្បន្ន កាលពីថ្ងៃទី ១៩ ធ្នូ ២០០៣ ជនភៀសខ្លួនខ្មែរកម្ពុជាក្រោម នៅព្រះរាជាណាចក្រ–កម្ពុជា រួមជាមួយជនរួមឈាមយើងមួយចំនួនទៀត ដែលកំពុងរស់នៅលើមាតុភូមិកម្ពុជាក្រោមបូកសរុប ចំនួន ១១ នាក់ បានធ្វើលិខិតមួយអបអរសាទរ ផ្ញើតាមរយៈវិទ្យុ–សំឡេងកម្ពុជាក្រោម ។ ខ្លឹមសារនៃលិខិតបានចាត់ទុកថាព្រឹត្តិការណ៍នេះ ជាជោគជ័យមានលក្ខណៈប្រវត្តិសាស្ត្ររបស់ប្រជាជាតិម៉ង់តាញ៉ា ។ ទោះបីយើងជាប្រជាជាតិផ្សេងគ្នាមែន តែមានប្រវត្តិសាស្ត្រជូរចត់ដូចគ្នា គឺត្រូវពួកអាណានិគមយួនជិះជាន់ ត្រួតត្រារាប់រយឆ្នាំមកហើយដូចគ្នា ។ ជាហេតុនាំឲ្យប្រជាជាតិខ្មែរកម្ពុជាក្រោមចូលរួមអបអរសាទរយ៉ាងកក់ក្តៅជាទីបំផុត និងប្រសិទ្ធិពរដល់ថ្នាក់ដឹកនាំ និងប្រជាជាតិម៉ង់តាញ៉ាទាំងមូល សូមឲ្យសម្រេចបានយ៉ាងឆាប់រហ័ស នូវសិទ្ធិសម្រេចវាសនាខ្លួនដោយខ្លួនឯង នៅលើមាតុភូមិរបស់ផងខ្លួន ៕ VOKK

# ពិធីបុណ្យរំឭកខួបឆ្នាំទី ៣ នៃអនិច្ចកម្មរបស់សម្ដេចបវរសេដ្ឋាធិបតី សឺនសាន

កាលពីព្រឹកថ្ងៃសុក្រ ទី ១៩ ខែធ្នូ ឆ្នាំ ២០០៣ នៅមជ្ឈមណ្ឌលកុមារកំព្រា សន្តិភាព ១ ស្រែអំពិល ឃុំឈើទាល ស្រុកកៀនស្វាយ ខេត្តកណ្ដាល មានប្រារព្ធពិធីបុណ្យទក្ខិណានុប្បទាន តាមគន្លងព្រះពុទ្ធសាសនាមួយក្រោមកិច្ចចាត់ចែងផ្ទាល់របស់លោក **សឺន ស៊ូប៊ែរ្ត** ប្រធានមូលនិធិសម្ដេចបវរសេដ្ឋាធិបតី **សឺន សាន** ដើម្បីរំឭកខួបឆ្នាំទី ៣ នៃមរណភាពរបស់សម្ដេច **សឺន សាន** អតីតទីប្រឹក្សាជាន់ខ្ពស់នៃព្រះមហាក្សត្រខ្មែរ ។

ពិធីនេះបានប្រព្រឹត្តទៅយ៉ាងមហោឡារិក ដោយមានការអញ្ជើញចូលរួម ពីសំណាក់ក្រុមញាតិមិត្តជិតឆ្ងាយ និង ក្រុមគ្រួសារផ្ទាល់របស់សម្ដេចបវរសេដ្ឋាធិបតី **សឺន សាន** ។ ក្នុងនោះគេក៏ពិនិត្យឃើញមានមន្ត្រីអ្នកមុខអ្នកការនៃអតីតរណសិរ្សជាតិរំដោះប្រជាពលរដ្ឋខ្មែរ អតីតគណ–បក្សប្រជាធិបតេយ្យសេរីនិយមព្រះពុទ្ធសាសនា និងអតីតគណបក្សលោកតា **សឺន សាន** ដូចជាលោកឧត្តមសេនីយ៍ **អៀវ ជួតិមម៉េង**. លោក **គៀត សុគន្ធ** អតីតរដ្ឋមន្ត្រីក្រសួងកិច្ចការនារី. លោក **គឹម សុខា** អតីតអគ្គលេខាធិការគណ–បក្សលោកតា **សឺន សាន** និងជាអតីតសមាជិកព្រឹទ្ធសភា. លោក **សាប៊ូ បាចា** សមាជិកព្រឹទ្ធសភា និងជាអតីតអនុ–ប្រធានទី ២ នៃគណបក្សលោកតា **សឺន សាន** ។ លោក **សុន ឆ័យ** អតីតសមាជិកគណបក្សប្រជាធិបតេយ្យសេរី–និយមព្រះពុទ្ធសាសនា ព្រះអង្គម្ចាស់ក្សត្រីយ៍ **ស៊ីសុវត្ថិ ពង្សនារី មុនីពង្ស**. លោក **នឹង ស៊ិន** អតីតអ្នកតំណាងរាស្ត្រ និងលោក **នៅ កាស៊ី** អ្នកនាំពាក្យគណបក្សហ៊្វុនស៊ិនប៉ិច ផងដែរ ។

ក្នុងឱកាសនោះ ក៏បាននិមន្តព្រះសង្ឃ ៩ អង្គ ចម្រើនព្រះបរិត្ត បង្សុកូល សម្ដែងធម៌ទេសនា រាប់បាត្រប្រគេនព្រះសង្ឃ ជាកិច្ចបង្ហើយបុណ្យ ។

តាមកម្មវិធីបានគ្រោងទុក នៅក្នុងរាត្រីនោះ នឹងមានបាញ់កាំជ្រួច និងសម្ដែងល្ខោនបាសាក់ កំដររាត្រីផង ៕

***តាំង សារៈ***

# ឧត្តមគតព្រះពុទ្ធឃោសាចារ្យ ឥម គុក ចើខ

> *“ព្រះអង្គមានចិត្តជាសប្បុរស មានសំដីជាប្រយោជន៍ មានព្រហ្មចារិយភាព ចំពោះជាតិ និងព្រះពុទ្ធសាសនាខ្មែរកម្ពុជាក្រោម”*

–សេចក្ដីល្អចេញមកពីចិត្តសប្បុរសធម៌ គឺជាស–កម្មភាព ដែលព្រអង្គមិនមែនធ្វើតែម្ដងដោយចៃដន្យទេ គឺធ្វើរាល់ថ្ងៃ ។

–សប្បុរសធម៌ គឺជាមនោសញ្ចេតនានៃសេចក្ដីល្អជាទង្វើដ៏ក្លៀវក្លា ដែលចេញមកពីមនសិការជាដរាបនៅក្នុងចិត្តរបស់ព្រះអង្គ ។

ការផ្ដើមធ្វើដំបូងរបស់ព្រះអង្គ ជាអាចារ្យបង្រៀន និងជា អនុប្រធានសមណាធិការខេត្តព្រះត្រពាំង នាឆ្នាំរកាបញ្ចស័ក ព.ស. ២៥០០ ។



# ព្រះពុទ្ធឃោសាចារ្យ

# គឹម ត្មុក ចេឹង

*-មេគណខេត្ត ព្រះត្រពាំង ។*

*-ប្រសូត្រនៅឆ្នាំរកាឯកស័ក ព.ស. ២៤៧៦ ។*

*-ព្រះអង្គសុគតនៅថ្ងៃ ២រោជ ខែមិគសិរ្ស ត្រូវនឹងថ្ងៃទី ១៧ ធ្នូ ឆ្នាំ ខាល ចត្វាស័ក ព.ស. ២៥២៩ ដោយពួកយួនកុម្មុយនិស្តពុះទ្រូង រូង យកបេះដូងរបស់ព្រះអង្គ ។*

ករណីយកិច្ចកំពូលនៃអំពើល្អ ឬសប្បុរសធមិរបស់ព្រះអង្គគឺ ៖ ការទ្រទ្រង់ខាងផ្លូវចិត្ត ជំរុញទឹកចិត្តព្រះសង្ឃ និង ពុទ្ធបរិស័ទឲ្យខិតខំសិក្សារៀនសូត្រអក្សរសាស្ត្រជាតិ ការពារថែរក្សាវប្បធមិជាតិឲ្យបានគង់វង្ស ។ ព្រះអង្គធ្វើឲ្យមានការអភិវឌ្ឍផ្នែកពុទ្ធិកសិក្សា គឺពង្រឹង និងពង្រីកសាលាធម្មវិន័យថ្នាក់ត្រី-ទោ-ឯក សាលាបាលីទី១-ទី២-ទី៣ ប្រជាសិក្សាសម្រាប់រៀនពេលយប់ ហើយនិងបឋមសិក្សានៅគ្រប់វត្តអារាមទូទាំងខេត្តព្រះត្រពាំង ។ ទោះជាពេលនោះ រដ្ឋាភិបាលអាណានិគមយួន ***ង៉ោ ឌិញ យីម*** ហាមមិនឲ្យខ្មែររៀនអក្សរសាស្ត្រខ្មែរ និយាយភាសាខ្មែរយ៉ាងណាក៏ដោយ ការប្រឹងប្រែងតស៊ូដ៏តឹងតែងស្វិតស្វាញនេះជាហេតុធ្វើឲ្យព្រះអង្គត្រូវរដ្ឋាភិបាល ***ង៉ោ ឌិញ យីម*** ចាប់យកទៅធ្វើទារុណកម្ម ដោយយកដែកដុតភ្លើងឲ្យឆេះក្រហមឆ្អៅ យកមកដុតដៃរបស់ព្រះអង្គឲ្យឆេះហុយទ្រលោម យ៉ាងឈឺចាប់ជាទីបំផុត ព្រះអង្គធ្លាប់មានសង្ឃដីកាអំពីរឿងនេះថា **«ពេលយួនដុតដៃ មិនមែនមិនឈឺនោះទេ តែបើស្រក់ទឹកភ្នែក នាំឲ្យខ្មាស់សត្រូវ»** ។

ឆ្នាំរការ សប្តស័ក ព.ស ២៥១២ ព្រះអង្គបានបង្កើតឲ្យមានសាលាធម្មគុរុវិជ្ជាថ្នាក់គរុកោសល្យទី ១ និង ទី ២ គឺជាឆ្នាំដែលយួនប៉ុនប៉ងធ្វើឃាតព្រះអង្គ តាមរបៀបដាក់ថ្នាំបំពុល នៅវត្តនិគ្រោធារាម ជ្រៃប្រាសាទ ជាវត្តដែលព្រះអង្គធ្វើជាសាស្ត្រាចារ្យបង្រៀនសមណនិស្សិត ថ្នាក់គរុកោសល្យទី ១ ប៉ុន្តែថ្ងៃដែលយួនយកថ្នាំមកបំពុលតាមចង្ហាន់ (អាហារ) នោះ ព្រះអង្គបាននិមន្តចេញពីវត្តជ្រៃប្រាសាទ ទៅបង្រៀនព្រះសង្ឃនៅសាលាធម្មវិន័យថ្នាក់ឯក ឯវត្តសុវណ្ណទេព្វឹឯកវិលារាម ដំបងពាក់ ព្រះអង្គក៏បានរួចផុតអំពីឃាតកម្មនេះ ចំណែកសមណនិស្សិតចំនួន ១៩ អង្គ ដែលគង់នៅរៀនក្នុងវត្តជ្រៃប្រាសាទទាំងអស់ ក៏ត្រូវថ្នាំបំពុលនេះចំនួន ១៨ អង្គ មានតែសាមណេរមួយអង្គប៉ុណ្ណោះមិនត្រូវថ្នាំបំពុល ព្រោះសាមណេរអង្គនេះមានអាពាធជាទម្ងន់ មិនអាចឆាន់ចង្ហាន់បាន ។ សមណនិស្សិត ១៨ អង្គមិនសុគតភ្លាមៗ ទេ ប៉ុន្តែមានជំងឺរីងរៃត្រូវសុគតជាបន្តបន្ទាប់នៅពេលក្រោយ ។

ព្រះអង្គបានអប់រំព្រះសង្ឃ ឲ្យប្រតិបត្តិធមិវិន័យបានយ៉ាងត្រឹមត្រូវ ហ្មត់ចត់ជាទីបំផុត រៀបចំមានសណ្តាប់ធ្នាប់នៅគ្រប់វត្តក្នុងការប្រារព្ធបុណ្យទានតូចធំ ក្នុងព្រះពុទ្ធសាសនា ក៏ដូចជាបុណ្យប្រពៃណី ។ រៀបចំឋានានុក្រមព្រះសង្ឃ និងគណៈកម្មការឧបាសក ឧបាសិកាចំណុះជើងវត្តតាមប្រព័ន្ធសង្ឃាភិបាលយ៉ាងច្បាស់លាស់ ។

ព្រះអង្គដឹកនាំព្រះសង្ឃ និងពុទ្ធបរិស័ទក្នុងការជួយគ្នាទៅវិញទៅមក គ្មានការច្រណែនឈ្នានីសប្បុស្សា គ្មានការនិយាយដើមគេ ឬការមូលបង្កាច់ និងសំអប់ ។

ព្រះអង្គមានមនោសញ្ចេតនាចំពោះភិក្ខុ សាមណេរ និងពុទ្ធបរិស័ទ ព្រមភាពជិតស្និត សេចក្តីរាប់អាន យុត្តិធមិក្នុងការងារ សេចក្តីប្រោសប្រណី កតញ្ញូក្នុងផលកិច្ចការដែលផ្តល់មក ។

ព្រះអង្គរៀបចំឲ្យមានរបៀបធ្វើកត្តវេទីចំពោះ ឧបជ្ឈាយាចារ្យ និងបុព្វបុរសជាតិ ។

**ចិត្តជាសប្បុរស សំដីជាប្រយោជន៍ និងព្រហ្មចរិយភាព ចំពោះជាតិ និងព្រះពុទ្ធសាសនា គឺជាករណីកិច្ចរបស់ព្រះអង្គ** នេះហើយដែលជាសភាវនីតិគ្មានឧត្បាតចំពោះជាតិ ដូចឃ្មុំមានក្បាលទឹក មធុរសមានតម្លៃ ។ ព្រះអង្គមានប្រយោជន៍សម្រាប់ខ្មែរកម្ពុជាក្រោម ទោះជាព្រះអង្គត្រូវយួនពុះទ្រូងរូងយកបេះដូងផ្តាច់ ផ្តិលជីវិតព្រះអង្គក៏ដោយ ៕

(នៅមានត)

*ផាច់ សុរិយា*

## សាគល្បខញ្ញាគរណ៍

# អំពីជោគវាសនា នៃរបបអាណានិគមយួន លើទឹកដីកម្ពុជាក្រោម

កម្ពុជាក្រោមពីយូរយារណាស់មកហើយ ជាដែនដីស្ថិតក្នុងអាណាចក្រកម្ពុជាគឺជាផ្នែកទាំងស្រុងនៃបូរណ-ភាពទឹកដីខ្មែរ ។

បារាំងបានចូលត្រួតត្រា[១] ដាក់អាណានិគមលើមាតុភូមិកម្ពុជាក្រោម ហើយបានហៅទឹកដីនេះថា កូសាំងស៊ីនទំនាប (sasse cochinchine) ឬកូសាំងស៊ីនបារាំង (cochinchine francaise) ជំនួសពាក្យ កូសាំងស៊ីនលើ (houte cochinchine) ឬកូសាំងស៊ីនអណ្ណាម ។

កូសាំងស៊ីន គឺជាពាក្យពួកអឺរ៉ុបយកទៅប្រើដើម្បីហៅដីដែលក្សត្រក្រុងវ៉េសន្តតិវង្សង្វៀងត្រួតត្រា គឺប្រទេសអណ្ណាមកណ្តាល (នគរចំប៉ា) ហើយនិងដីសណ្តដូណាយ (donai) និងទន្លេមេគង្គ ដែលយួនប្លន់ពីខ្មែរ ។

ពួកយួនដាក់ឈ្មោះដែនដីកម្ពុជាក្រោមនេះ ថា ណាំគី (nam ky) ឬ ណាំបូ (nam bo) ។

ការវាតទីតាំងនៃនិគមជនយួន (អណ្ណាម) ដែលចេញមកពីភូមិភាគតុងកឹងបានសម្រុកចុះមកភូមិភាគខាងត្បូងបានលេបត្របាក់នគរចំប៉ា រហូតដល់នគរចំប៉ាវលាយបាត់ឈ្មោះពីផែនទីពិភពលោកនៅ គ.ស. ១៦៩៦ ។

ការចូលមកក្នុងសន្តតិវង្សខ្មែរនៃក្សត្រ ត្រកូលង្វៀង នា គ.ស. ១៦១៨ គឺដោយអាស្រ័យក្សត្រកូលនេះ ហើយ ទើបបានជាគណៈប្រតិភូអណ្ណាមមួយបានទទួលពីព្រះបាទជ័យជេដ្ឋាទីពីរនៅ គ.ស. ១៦២៣ នូវការអនុញ្ញាតឲ្យបង្កើតកុងត្វាជំនួញនៅប៉ែកខាត្បូងបំផុត នៃព្រះរាជាណាចក្រខ្មែរ គឺតាំងហាងជំនួញនៅកំពង់ក្របី (ព្រៃនគរបច្ចុប្បន្ន) និងមួយស៊ុយ ព្រមទាំងទទួលសិទ្ធិរួចព័ន្ធគយនិងរដ្ឋាករនៅព្រៃនគរ ។

តាមចុតហ្មាយរបស់ក្សត្រយួនពេលនោះ បានឲ្យដឹងថា ប្រទេសអណ្ណាមបានសុំប្រើប្រាស់ដីកំពង់ក្របីនិងមួយស៊ុយ (moi xuy) យួនហៅម៉ស្វាយនេះតែក្នុងរយៈពេលប្រាំឆ្នាំប៉ុណ្ណោះ ។ ដោយប្រទេសអណ្ណាមបានអាងហេតុផលថា ខ្លួនត្រូវការសំចតទ័ពដើម្បីស្លអារុធ ។

គ.ស. ១៦៤៥ ព្រះបាទអង្គតូ និងគ.ស. ១៦៥៣ ព្រះបាទអង្គច័ន្ទ សុំឲ្យស្តេចអណ្ណាមប្រគល់កោះក្របី និងមួយស៊ុយមកឲ្យខ្មែរវិញតែក្សត្រីយ៍ ជូ ជាតិអណ្ណាមមេម៉ាយពីព្រះបាទជ័យជេដ្ឋាទីពីរមិនព្រមឲ្យ ។ ដូច្នេះដីទាំងពីរចំណែកដ៏ធំនោះ បានធ្លាក់ចូលទៅក្នុងដៃយួនអណ្ណាមដោយឧបាយកល ។ ស្តេចខ្មែរមិនដែលបោះបង់កម្មសិទ្ធិនេះទៅឲ្យយួនម្តងណាឡើយ ។

ចំពោះគោលការណ៍បន្តមរតក ប្រសិនណាបើយើងសន្មត់ថាសេចក្តីអនុញ្ញាតកាន់កាប់កោះក្របី និងមួយស៊ុយ អាចកែប្រែទៅជាសិទ្ធិផ្តាច់មុខក៏ដោយចុះ ក៏គេពុំត្រូវភ្លេចទេថាសិទ្ធិនេះគ្រាន់តែជាសិទ្ធិបុគ្គលប៉ុណ្ណោះ ។ មិនអាចបង្កើតបានជាកម្មសិទ្ធិណាមួយ សម្រាប់សាមីជនឡើយ ។ តាមច្បាប់ខ្មែរ សិទ្ធិនេះនឹងរលត់ទាំងស្រុងទៅតាមមរណភាពរបស់សាមីជន ។

ដូច្នេះទឹកដីទាំងនោះយួនអណ្ណាមកាន់កាប់ ត្រួតត្រា ដោយការឈ្លានពានខុសនឹងច្បាប់អន្តរជាតិបច្ចុប្បន្នដែលបណ្តាប្រទេសទាំងឡាយ ជាហត្ថលេខីមានយួនជាដើមត្រូវតែគោរពបូរណភាពទឹកដីនៃប្រទេសជិតខាង ។

ក្រោយ គ.ស. ១៦៣៧ តាមជម្លោះក្នុងសន្តតិវង្សខ្មែរ ក្សត្រីយអណ្ណាមមេម៉ាយពីព្រះបាទជ័យជេដ្ឋាទី ២ គឺជាមេខ្យល់ញុះញង់សុំការធ្វើអន្តរាគមន៍ ពីស្តេចអណ្ណាមព្រះចៅអណ្ណាមបានបញ្ជូនកងទ័ពស្ថិត ក្រោមបញ្ជាការឧត្តមសេនីយ៍ អុង ជៀង ធូ (ong cheng thu) ចូលអាណាចក្រកម្ពុជា តាមរយៈមេខ្យល់នេះ ។

-គ.ស. ១៦៨៩ យួនអណ្ណាមសន្តតិវង្សង្វៀងបានបញ្ជូនទ័ពចំនួន ២០.០០០ នាក់ លើកព្យុហយាត្រាសំដៅមកកាន់ភ្នំពេញ ក្រោយពេលដែលបរាជ័យទ័ពយួនដែលសល់ពីងាប់ មិនចូលប្រទេសអណ្ណាមវិញទេ ត្រឡប់ចូលទៅតាំងទីលំនៅនៅកូសាំងស៊ីន ។

(១) *សម្រង់ចាកឯកសារ «កូសាំងស៊ីនជាដែនដីរបស់ខ្មែរ យួនត្រូវតែសងឲ្យខ្មែរវិញ» របស់លោក សាង ម៉ាក់ សាង ។*

គ.ស. ១៦៩៩ ទ័ពយួនចំនួន ២០.០០០ នាក់ទៀតចេញពីកូសាំងស៊ីនទៅដល់ទន្លេសាប ក្រោយពេលដែលបរាជ័យមិនចូលទៅប្រទេសអណ្ណាមវិញទេ គឺទៅជ្រកនៅខេត្តកំពប់ស្រកាត្រី (បៀងហ្វា) បារៀ និងព្រៃនគរ ។

គ.ស.១៧៣០ យួនអណ្ណាមលើកទ័ពវាយប្រទេសកម្ពុជា ក្នុងបទថាជួយយួនរស់នៅក្រោមច្បាប់ខ្មែរ ពេលបរាជ័យ ទ័ពយួនទាំងនោះមិនត្រឡប់ចូលអណ្ណាមវិញទេ ត្រឡប់ទៅតាំងទីលំនៅកូសាំងស៊ីន ។

គ.ស. ១៧៤៣ ទ័ពយួនអណ្ណាមវាយចូលខេត្តបាសាក់ យួនបរាជ័យទៅពួននៅកោះហុង (The ca-hong) ខេត្តពាមមេសរ ។

គ.ស. ១៧៤៨ អធិរាជក្រុងអណ្ណាមបានបញ្ជូនទ័ពទៅច្បាំងខេត្តទ្រាំង (បាសាក់) កំចាត់ចៅហ្វាយខេត្តបាសាក់បរាជ័យ យួនបញ្ជូនទ័ពទៅជិតក្រុងឧត្តុង្គ ។ ប៉ុន្តែត្រូវក្រឡាហោមអុក (oc) និងចៅហ្វាយខេត្តពោធិសាត់ដឹកនាំទ័ពវៃឲ្យបរាជ័យ ទ័ពយួនទាំងនោះមិនចូលអណ្ណាមវិញទេត្រឡប់ជាចូលទៅបោះទីតាំងនៅកូសាំងស៊ីនវិញ ។

ក្រោយពីគិតទៅដឹងថា ខ្លួនមានចំនួនច្រើនល្មមហើយ ខ្លាំងល្មមហើយ ពួកយួនទាំងនោះក៏ចាប់ផ្តើមចែកដីទាំងនោះជាស្រុកតូចៗ ឋិតនៅក្រោមការត្រួតត្រារបស់មេទ័ពយួនម្នាក់ កាន់កាប់ទាំងអំណាចស៊ីវិលទាំងយោធាជាបន្តបន្ទាប់នូវខេត្តទាំងឡាយណា ដែលយួនវាយកាន់កាប់បាន ទោះជានៅក្នុងខេត្តយ៉ាងច្រើនខ្លះ ខ្មែរកាន់កាប់ជាផ្លូវការ មានងារជាចៅហ្វាយស្រុក ឬក្រឡាពាសក៏ដោយ ។

គ.ស. ១៧៥៨ ដើម្បីរ៉ាប់រងសន្តិសុខនៃការកាន់កាប់ដោយខុសច្បាប់នូវដែនដីដ៏ធំទូលាយរបស់ខ្មែរ ដែលយួនដណ្តើមឬបង្ខំឲ្យខ្មែរប្រគល់ឲ្យនោះ ពួកយួនអណ្ណាមបានកសាងបន្ទាយនៅសាដេក គុយឡៅយៀង (culao gieng) និងមាត់ជ្រូក ក្នុងការត្រួតត្រាបង្កើតឈ្មោះថ្មីសម្រាប់ឲ្យហៅខេត្តខ្មែរដែលដណ្តើមបាន ឯមន្ត្រីយួនទាំងនោះ ពុំមែនទទួលការតែងតាំងជំនួសមន្ត្រីខ្មែរសោះឡើយ ។ ការណ៍នេះអាចនិយាយបានថាជាការជ្រើសតាំងរវាងពួកយួនដោយមិនឲ្យខ្មែរដឹង ពីព្រោះពេលនោះយួនមិនបានធ្វើឫកពាជាអ្នកមានកិត្តិយសខ្ពស់ និងថ្នាក់ខាងសេដ្ឋកិច្ចល្អ គួរឲ្យគេជ្រើសរើសជាចៅហ្វាយនាយបានឡើយ ។ ដូចកាលប្បវត្តិរបស់យួនអណ្ណាមបានអះអាងថា ការសម្លាប់រង្គាលនៃជនជាតិអណ្ណាមនៅលើដីខ្មែរ ជាកិច្ចតម្រូវបញ្ជាក់ការចូលកាន់កាប់របស់យួន នូវខេត្តពាមមេសរ (មេថរ) និងខេត្ត លង់ហោរ (វិញឡុង) ជាខេត្តចាស់របស់ព្រះរាជាណាចក្រកម្ពុជា ។



*ទិដ្ឋភាពបច្ចុប្បន្ន នៃវត្តចន្ទរង្សី – ព្រៃនគរ*

គ.ស. ១៨៤១–១៨៤៥ សៀម និងយួនច្បាំងដណ្តើមឥទ្ធិពលគ្នាលើទឹកដីខ្មែរ ទ័ពយួនអណ្ណាមក្រោមកិច្ចបញ្ជាការរបស់មេទ័ពឈ្មោះ អុង ចាងឡាញ់ បិន (ong chang lanh binh) កងទ័ពសៀមក្រោមបញ្ជាការ មេទ័ពឈ្មោះ បូ ឌិញ ។ សង្គ្រាមក្រោយបំផុតនៅក្រុងលង្វែក ពេលនោះខ្មែរបានសម្លាប់មេទ័ពយួនឈ្មោះ អុង ចាងឡាញ់ បិន បានដូចបំណងទ័ពខ្មែរបានប្រើទ័ពដំរីកម្ទេចទ័ពយួនដែលបាក់នោះ ហើយចាប់បានមេទ័ពយួនម្នាក់ និងទាហានជាច្រើននាក់ទៀត ។

ក្រោយពីការទទួលបរាជ័យ ជាច្រើនលើកនិងប៉ុនប៉ងមិនបានសម្រេចជាច្រើនដងផង យួនអណ្ណាមបានសុខចិត្តចុះហត្ថលេខាសន្តិភាពជាមួយខ្មែរ ។ យួនអណ្ណាមបានដកកងទ័ពចេញពីដីខ្មែរនៅខែមិថុនា គ.ស. ១៨៤៦ ប៉ុន្តែកងទ័ពទាំងនោះមិនទៅប្រទេសអណ្ណាមវិញទេ ត្រឡប់ជាចូលទៅតាំងទីនៅកូសាំងស៊ីនដដែល ។

យួននិងបារាំង ធ្វើអាណានិគមមកលើខ្មែរកម្ពុជាក្រោមឥតបានធ្វើអ្វីដើម្បីខ្មែរសោះ តែត្រឡប់ជាសប្បាយចិត្តនឹងបញ្ចូលជាឧបសម្ព័ន្ធ នូវដីដែលពួកគេឈ្លានពានធ្វើអាណានិគមដីចំណុះខ្លួន ដោយលបធ្វើសន្ធិសញ្ញាជាមួយយួនចុះថ្ងៃទី ៥ មិថុនា ១៨៦២ ប្លន់យកអាណាខេត្ត

ខ្មែរទាំងឡាយនៅប៉ែកខាងកើត អាណាខេត្តផ្នែកនេះមានដូចតទៅ ៖

| ឈ្មោះរបស់ខ្មែរ | ឈ្មោះយួនកែប្រែ |
|---|---|
| ១-កំពប់ស្រកាត្រី | បៀនហ្វា |
| ២-ព្រៃនគរ | យ៉ាឌិញ |
| ៣-មេសរ | ឌិញ-ទួង |

និងកោះពូឡូកងឌ័រ ហើយនិងសន្ធិសញ្ញាចុះថ្ងៃទី ១៥ មិនា គ.ស. ១៨៧៤ ប្លន់យកអាណាខេត្តខ្មែរនៅប៉ែកខាងលិច អាណាខេត្តទាំងឡាយនៅផ្នែកនេះគឺ ៖

| ឈ្មោះរបស់ខ្មែរ | ឈ្មោះយួនកែប្រែ |
|---|---|
| ១-លង់ហោរ | វិញឡុង |
| ២-មាត់ជ្រូក | អានយ៉ាង |
| ៣-ពាមឬម្លូងខាំ | ហាទៀង |

ហេតុការណ៍ទាំងឡាយជាប្រវត្តិសាស្ត្រ ចង្អុលបង្ហាញថា ប្រទេសកម្ពុជាឥតយល់ព្រមបោះបង់ចោលកម្មសិទ្ធិលើដីនោះ (កម្ពុជាក្រោម) ព្រមទាំងប្រវត្តិវិទូធំៗទទួលស្គាល់ឯកច្ឆន្ទថា ជាដីរបស់ខ្មែរ ។ លើសពីនេះទៀត នៅមុនពេលបារាំងចូលត្រួតត្រាដីនោះ វាពុំមានព្រំដែនខ័ណ្ឌប្រទេសកម្ពុជាបច្ចុប្បន្ននិង កូសាំងស៊ីនទំនាបសោះទេ ។ ហេតុនេះសឲ្យឃើញថាមកទល់នឹងបារាំងចូលត្រួតត្រាយួនពុំអាចធ្វើឲ្យដីខ្មែរផ្នែកនេះជាដីរបស់ខ្លួន ហើយនឹងធ្វើខ្លួនឲ្យទៅជាម្ចាស់ផុតសិទ្ធិតវ៉ាបានឡើយ ។

អំឡុងពេលនៃការត្រួតត្រារបស់យួន និងបារាំង ខ្មែរបានប្រយុទ្ធប្រឆាំង ទាមទារគ្រប់ពេលវេលាជាបន្ត-បន្ទាប់ ដែលប្រវត្តិសាស្ត្របានកំណត់ច្បាស់អំពីបញ្ហានេះ។

បើទោះណាជានៅក្នុងការកាន់កាប់នោះ បញ្ហាកូសាំងស៊ីន ហាក់ដូចជាបានដោះស្រាយស្រឡះហើយ រវាងប្រទេសបារាំងនិងកម្ពុជា ហើយដូចគ្នានេះដែររវាងប្រទេសកម្ពុជា និងយួនអណ្ណាមក៏យើងបានទាមទារសិទ្ធិជាម្ចាស់ដីជាច្រើនលើកច្រើនសា ដោយកម្លាំងអាវុធបន្ទាប់មកដោយកិច្ចចរចារ (ខកចិត្ត) ជាមួយប្រទេសបារាំង ។ តមកគឺក្រោយពីសៀមដណ្តើមយកខេត្តបាត់-ដំបង និងសៀមរាបក្នុងឆ្នាំ ១៩៤១ គណៈរដ្ឋមន្ត្រីខ្មែរបានទៅស្រុកបារាំងដើម្បីទាមទារដីកូសាំងស៊ីន ។ ប៉ុន្តែត្រូវខកចិត្តទៀតដោយសារតំណាងប្រទេសបារាំង នៅកម្ពុជារារាំង ។

កាលពីថ្ងៃទី ២២ កញ្ញា គ.ស ១៩៦១ ដែលសម្តេចព្រះនរោត្តម សីហនុ ព្រះមុខរដ្ឋកម្ពុជាទ្រង់បានរំឭកនៅចំពោះមុខអង្គការសហប្រជាជាតិ ព្រះអង្គមានព្រះបន្ទូលថា កាលពីឆ្នាំ ១៩៤៦-៤៧ ដោយហេតុប្រទេសបារាំង ត្រូវតស៊ូបង្ក្រាបការបះបោររបស់ វៀត-ណាម ដែលមានកម្លាំងជាពិសេសប៉ែកខាងជើងនោះ ប្រទេសបារាំង ក៏បង្កើតឲ្យមានរដ្ឋាភិបាលបណ្តោះអាសន្នមួយនៅវៀតណាមខាងត្បូង ។ រួចកាលពីឆ្នាំ ១៩៤៨-៤៩ ប្រទេសបារាំងបានហៅ បាវ ដាយ ជាអតីតមហាក្សត្រដែលត្រូវដាក់រាជ្យកាលពីឆ្នាំ ១៩៤៥ នោះមកវិញ បានប្រកាសតែងតាំង បាវ ដាយ ឲ្យធ្វើជាប្រមុខរដ្ឋហើយផ្ទេរកូសាំងស៊ីនជាដីរបស់បារាំង មកឲ្យបាវដាយដោយមានសេចក្តីយល់ព្រមរបស់រដ្ឋសភាបារាំងផង។ ព្រះមហាក្សត្រកម្ពុជា ព្រះអង្គទ្រង់ក៏បានតវ៉ាជាផ្លូវការជំទាស់នឹងការផ្ទេរដែនដីនេះ ដែលប្រទេសរបស់យើងបានរក្សាសិទ្ធិរបស់ខ្លួនត្រឹមត្រូវតាមច្បាប់នៅដែនដីនោះ តែការតវ៉ានេះជាការឥតអំពើ ។

បច្ចុប្បន្ន សកម្មភាពប្រយុទ្ធ ប្រឆាំងដោយសន្តិវិធីអហឹង្សារបស់ខ្មែរក្រោមនៅគ្រប់ទីកន្លែងទូទាំងពិភពលោក គឺដើម្បីបញ្ចប់កង្វល់ទាំង ៦ យ៉ាង(២)ដែលបានចែងនៅក្នុងលិខិតរបស់លោក Marino Busdachin ប្រធានអង្គការ UNPO ចុះថ្ងៃទី ២ កញ្ញា ២០០៣ ផ្ញើទៅមេដឹកនាំក្រុង ហាណូយ នឹងទទួលបានការគាំទ្រពីបណ្តាប្រទេសនិងអង្គការនានាដែលស្នេហាសន្តិភាព និងយុត្តិធម៌ក្នុងលោកនេះពុំខានឡើយដោយសំអាងទៅលើភស្តុតាងនានាគឺ ៖

១-ទទ្បីករណ៍(សំអាង)ផ្អែកលើសិល្បៈនិងវប្បធម៌ ។
២-ទទ្បីករណ៍(សំអាង)ផ្អែកលើអត្តបទនឹងផែនទី ។
៣-ទទ្បីករណ៍(សំអាង)ផ្អែកលើប្រវត្តិសាស្ត្រ ។
៤-ទទ្បីករណ៍ផ្អែកលើគតិយុត្តិ ។
៥-ទទ្បីករណ៍ផ្អែកលើរដ្ឋបាល ។
៦-ទទ្បីករណ៍ផ្អែកលើជាតិពន្ធុ ។

***ថាច់ សូរិយា***

(២) *ចែងពិស្តារនៅក្នុងព្រឹត្តិបត្រ* កម្ពុជាក្រោម *លេខ ០១ ខែមករា ឆ្នាំ ២០០៤ ទំព័រ ០៣ ។*

កំណាព្យ

# ទំនួញព្រះត្រពាំង

(តពីលេខមុន)　ឆ្លងខាលចូលថោះ
កុម្មុយនិស្តរំដោះ　ជំលោះយួនចប់　សង្គ្រាមឃោរឃៅ
ត្រូវបានបញ្ចប់　យួនកុម្មុយនិស្តលប លេបយកដាច់ក្រឹប ។
　កុម្មុនិស្តគេខ្លាំង
ឈ្នះអាមេរិចកាំង　តាំងផ្ដើមអូសរឹប　ភូមិចំការខ្មែរ
ស្រែទូលដីទាប　ខ្មែរក្រោមរលាប　កប់ផុងលង់ខ្លួន ។
　ពួកយួនកុម្មុនិស្ត
រិះរកគំរិះ　របេះចាកក្បួន　គេបានចំណី
ឆីលាក់បំពួន　រាស្ត្រខ្មែរងាប់ខ្លួន　យួនចោរងាប់ឈ្មោះ ។
　រំដោះបានដី
យួនគិតសារថ្មី　លែយកឈ្មោះចាស់ ហៅថាត្រាវិញ
ចេញពីកុម្មុយនិស្ត　ប្រាប់រាស្ត្រទាំងអស់ ស្គាល់ឈ្មោះពីមុន ។
　ទឹកដីត្រាវិញ
យួនបានដូរចេញ　វិញត្រាឲ្យសូន្យ　កុំឲ្យខ្មែរស្គាល់
ដល់ឈ្មោះកាលមុន　ប្រែជាពាក្យយួន　ចូនរូមខែត្រពីរ ។
　ខែត្រមួយវិញឡុង
ត្រាវិញខាងត្បូង　វេញផ្លុងត្រង់ទី　ងាយយួនកាន់កាប់
ក្ដោបក្ដាប់ផែនដី　រួចហើយកំចាយ　ប្រល័យខេមរា ។
　វិញឡុងឡុងហោរ
ត្រាវិញរួមមក　ឆហៅវិញត្រា　ខែត្រមួយដោយឡែក
ចែកខ្មែរត្រួតត្រា　ស្រួលមាត់យួនថា　វិញត្រាឈ្មោះថ្មី ។
　ពួកយួនឫស្សា
លាក់ពុតដូចឆ្មា　ស្រវាកកាយ　រូបរួមខែត្រពីរ



ទីព្រំមុមដី　ខ្មែរលែងសង្ស័យ　កាឡាយវាចា ។
　វិញត្រាស្រួលហៅ
បោកខ្មែរល្ងង់ខ្លៅ　ចារក្រៅតម្រា　យួនផ្លាស់ប្ដូរប្រែ
កែងាយត្រួតត្រា　បំបាត់ខេមរា　តាដូនសូន្យសុង ។
　យួនបំពួនកល
សង្ស័យងឿងឆ្ងល់　ដល់កាលកន្លង　វាយល្បិចដាក់ល្បោយ
ឲ្យឈ្មោះគីវឡុង　ត្រាវិញវិញឡុង　ក្នុងអំណាចយួន ។
　គីវឡុងអន្លង់កម្ម
ប្រែឲ្យខ្មែរតាម　ចាំកុំភ្លេចខ្លួន　ឈ្មោះល្អសែនគាប់
រាប់ដាក់ប្រាំបួន　ខ្មែរមិនតាមយួន　ចូនហៅមេគង្គ ។
　ឃើញខ្មែរចេះដឹង
យួនលោះព្រលឹង　ខឹងផ្លាស់គីវឡុង　បំបែកត្រាវិញ
ចេញពីវិញឡុង　រត់តាមគន្លង　អ្នកផងគេស្គាល់ ។
　ពេលនេះឥឡូវហ្នឹង
ត្រពាំងទន្ទឹង　សម្លឹងចាំកាល　សហព័ន្ធខ្មែរ
ដង្ហែមកដល់　កាន់កាប់ទទួល　ថែរក្សារូបខ្ញុំ ។
　ខ្ញុំដង្ហោយហៅ
ខ្មែរចេញទៅក្រៅ　មកនៅជួបជុំ　កៀកកើយនៃបនិត្យ
អាណិតរូបខ្ញុំ　ដីកម្ពុជាក្រោម　មាតុភូមិដូនតា ។
　ទន្ទឹងសែនយូរ
មិនទាន់ឃើញមក៍　ចោរវាប្រហារ　ឬមានទុក្ខសោក
រោគាឈឺផ្សា　ព្រួយនឹងមរណា　យ៉ាងណាហើយម្ចាស់ ។
　បើម្ចាស់បានសុខ
វិលទៅចូលស្រុក　ត្រពាំងអរណាស់　យួនលែងរុករើ
ធ្វើការប្ដូរផ្លាស់　ត្រពាំងមានម្ចាស់　គ្រប់គ្រងរក្សា ។
　ជយោៗ !
ទទួលអំណរ　ប្រជាខេមរា　លោកខំតស៊ូ
ប្ដូរទាំងជីវ៉ា　ដើម្បីទាមទារ　សិទ្ធិសេរីភាព ៕
　(ចប់)

ថាច់ សុមេធ

---

សេចក្ដីកែសម្រួល ៖ ច្បាប់ចុះលេខ ០១ ឆ្នាំទី ០១ ក្នុងអត្ថបទកំណាព្យ ទំព័រ ៨ ពាក្យថា ស្រះនៅខាងដើម សូមកែថា ព្រះនៅខាងដើម ។

## ប្រលោមលោកផ្ទែកមនោសញ្ចេតនា

# រឿង ខាសនាម្សៅខ្មែរក្រោម

ដោយ លោក តាំង សារៈ

### វគ្គទី ១
### ជួបគ្នាគ្រាដំបូង

ជួប អូនដំបូងនៅហាងបាយ
ឃើញភ័ក្ត្រឆោមឆាយល្អគយគន់ ។
គ្រា ដែលបងជួបសែនចៃដន្យ
បងតែងគយគន់មិនជិនណាយ ។
ដំ បូងគ្រាន់តែនឹកអាណិត
ក្រោយមកប្រតិព័ទ្ធមិនរសាយ ។
បូង សំរូងសូមជួបស្រស់ឆោមឆាយ
តែយើងពីរកាយសែនឆ្ងាយគ្នា ។





វិបុល គឺជាអតីតនិស្សិតមហាវិទ្យាល័យវេជ្ជសាស្ត្រ ឱសថសាស្ត្រ និងទន្តសាស្ត្រមួយរូប ដែលទើបតែប្រឡងចេញ ពីមហាវិទ្យាល័យនេះ នាចុងឆ្នាំ ១៩៦៩ គឺមុនពេលដែលលោកឧត្តមសេនីយ៍ លន់ ណុល ធ្វើរដ្ឋប្រហារសម្តេចនរោត្តមសីហនុ តែប៉ុន្មានខែប៉ុណ្ណោះ ។

ក្រោយពីប្រឡងជាប់រួចហើយ វិបុលស្វែងរកការងារពុំទាន់បានធ្វើផង គាប់ជួនជាពេលនោះ ប្រទេសកម្ពុជា ធ្លាក់ចូលក្នុងសភាពច្របូលច្របល់ ដោយសង្គ្រាមរវាងកងទ័ពរដ្ឋាភិបាលសាធារណរដ្ឋខ្មែរ របស់លោក លន់-ណុល និងកងទ័ពឧទ្ទាម ដែលមាន ២ ក្រុម គឺក្រុមខ្មែរក្រហម និង ក្រុមវៀតកុង វៀតណាមខាងជើង ។

ក្នុងកាលៈទេសៈ ដែលប្រទេសជួបកលយុគបែបនេះវិបុលក៏សម្រេចចិត្ត ចូលបម្រើក្នុងជួរកងទ័ពជាយុទ្ធជន មួយរូបនៃកងយោធពលខេមរជាតិ (FANK) របស់លោក លន់-ណុល ក្នុងឋានៈជាពេទ្យទាហានមួយរូប តាមសេចក្តីអំពាវនាវរបស់ប្រទេសជាតិ ។

គេពុំបានដឹងថា ឪពុកម្តាយរបស់វិបុល មានជាប់ឈាមជ័រជាមួយនិងខ្មែរកម្ពុជាក្រោមដែរឬអត់នោះទេ ? ប៉ុន្តែចំពោះវិបុលវិញ មានដើមកំណើតនៅភូមិខ្នាចរមាស ស្រុកបវេល ខេត្តបាត់ដំបង ប៉ុន្តែនិស្ស័យរបស់វិបុល ចូលចិត្តរាប់អាន និងចូលចិត្តសិក្សាស្រាវជ្រាវ អំពីប្រវត្តិសាស្ត្រ ភូមិសាស្ត្រ និងព្រឹត្តិការណ៍ផ្សេង ៗ នៅដែនដីកម្ពុជា-ក្រោមណាស់ ។

ស្របពេលដែលវិបុលចូលបម្រើការ នៅក្នុងអង្គភាពពេទ្យទាហាន ក្នុងសម័យសាធារណរដ្ឋខ្មែរ ដែលពេលនោះក្រុមទាហានម៉ៃហ្វករបស់ឯឧត្តម សឺន ង៉ុកថាញ់ ដែលសុទ្ធតែជាខ្មែរកម្ពុជាក្រោម ត្រូវបញ្ជូនមកធ្វើការជួយប្រយុទ្ធ តទល់ជាមួយនិងកងទ័ពយួនវៀតកុងវៀតណាមខាងជើងផងនោះ ធ្វើឲ្យវិបុលកាន់តែមានទំនាក់ទំនងបានស្គាល់ និងបានដឹងនូវព្រឹត្តិការណ៍ផ្សេង ៗ នៅកម្ពុជាក្រោមកាន់តែច្រើនឡើង ។

ទន្ទឹមនោះដែរ វិបុលក៏មានមិត្តភ័ក្រ្តយ៉ាងជិតដិតមួយរូបឈ្មោះ សឺន សំណាង ជាខ្មែរកម្ពុជាក្រោម មានដើមកំណើតនៅខេត្តព្រះត្រពាំង បច្ចុប្បន្នជាអ្នកយកព័ត៌មានជូនសារព័ត៌មាន «ទុក្ខខ្មែរក្រោម» ។

លោក សឺន សំណាង បានចាកចេញពីមាតុភូមិកំណើតតាំងពីឆ្នាំ ១៩៦០ ពេលគឺតាំងពីតរុណវ័យមកម្ល៉េះ ដោយមកស្នាក់នៅក្នុងកុដិរបស់ព្រះតេជព្រះគុណព្រះបាឡាត់កែវ នៅវត្តឧណ្ណាលោម ក្រុងភ្នំពេញ ។

មានវេលាល្ងាចថ្ងៃមួយ វិបុលនិងសំណាងបាន

បបួលគ្នាពិសារភេសជ្ជៈ នៅក្នុងហាងតូចមួយ ។ ក្នុងពេលកំពុងពិសារភេសជ្ជៈនោះ គេក៏ពិភាក្សាគ្នាលេងពីនេះ ពីនោះ ពេលនោះវិបុលក៏ផ្ដើមប្រយោគទៅកាន់សំណាងថា៖

-សំណាងហ្នា៎ គ្នាដូចជាចង់ស្គាល់ទឹកដីកម្ពុជា-ក្រោមបានម្ដង តើត្រូវរកវិធីណាដើម្បីទៅបាន ចូរសម្លាញ់ឯងជួយបង្ហាញគ្នាផងមើល ។

សំណាងគេអង្គុយសញ្ជឹងរំពឹងគិតមួយសន្ទុះ ទើបគេងើបមុខឡើង ហើយឆ្លើយទៅវិបុលវិញថា ៖

-អូ! គ្នានឹកឃើញហើយសម្លាញ់ ពេលនេះរដ្ឋសភាជាតិ កំពុងរៀបចំជាគណៈប្រតិភូ របស់រដ្ឋសភាជាតិមួយ ដែលដឹកនាំដោយលោក ដាញ់ សាង ដើម្បីចុះទៅធ្វើទស្សនកិច្ច និងសាកសួរសុខទុក្ខបងប្អូនខ្មែរកម្ពុជា-ក្រោម នៅខែខាងមុខនេះ ។

ចំណែកសារព័ត៌មាន «ទុក្ខខ្មែរក្រោម» ក៏ត្រូវបានគណៈប្រតិភូនេះ អញ្ជើញបុគ្គលិក ៣ រូប ចូលរួមដំណើរក្នុងឋានៈជាអ្នកយកព័ត៌មានផងដែរ ប៉ុន្តែពេលនេះលោកចាងហ្វាង ទើបតែជ្រើសរើសបានរូបគ្នាជាមួយ និងលោកតែប៉ុណ្ណោះ ដូច្នេះគ្នានិងទៅជម្រាបលោកឲ្យបញ្ចូលឈ្មោះសម្លាញ់ឯងម្នាក់ទៀត ច្បាស់ជាលោកមិនបដិសេធទេ ព្រោះលោកចាងហ្វាង និងវិបុលឯងក៏ធ្លាប់ស្គាល់គ្នាជិតដិតដែរ មិនថាអញ្ចឹងហី ? ។

ពេលនោះវិបុល គេសើចសប្បាយ ក្នុងក្ដីសង្ឃឹមថា នឹងបានស្គាល់ទឹកដីកម្ពុជាក្រោម និងបានយល់នូវអ្វីៗដែលគេធ្លាប់ស្រមៃឃើញក្នុងដួងចិត្តរបស់គេតាំងពីយូរយារណាស់មក ហើយនោះ ។

ថ្ងៃកំណត់នៃដំណើរទស្សនកិច្ច របស់គណៈ-ប្រតិភូរដ្ឋសភា នៃសាធារណរដ្ឋខ្មែរ ទៅកាន់ដែនដីកម្ពុជាក្រោមបានមកដល់ ដោយមានលោក ដាញ់-សាង អ្នកដំណាងរាស្ត្រមានដើមកំណើតនៅខេត្តក្រមួនស ជាអ្នកដឹកនាំ និងមានអស់លោកជាតំណាងសមាជិកខ្លះ មានដើមកំណើតនៅកម្ពុជា និង ខ្លះទៀតមានដើមកំណើតនៅកម្ពុជាក្រោមលាយចម្រុះគ្នា ក្នុងនោះក៏មានវិបុល និងសំណាងជាសមាជិកផងដែរ ។

គណៈប្រតិភូ បានអញ្ជើញទៅធ្វើទស្សនកិច្ចពិនិត្យអំពីស្ថានភាពរស់នៅ របស់បងប្អូនខ្មែរកម្ពុជាក្រោមលើគ្រប់វិស័យដូចជាវប្បធម៌ ទំនៀមទម្លាប់ ប្រពៃណី ភាសា អក្សរសាស្ត្រ សាសនា និងជីវភាពជាដើម ក្នុងខេត្តមួយចំនួនដូចជា ៖ ខេត្តព្រះត្រពាំង (វិញប៊ិញ) ខេត្តក្រមួនស (កៀនយ៉ាង) និង ខេត្តឃ្លាំង (បាស្សៀង) ជាដើម ។

អាស្រ័យដោយរូបគេ (វិបុល) ចង់ស្គាល់ចង់ដឹងឲ្យបានច្រើនអំពីស្ថានភាពទឹកដីនិងប្រជារាស្ត្រខ្មែរនៅដែនដីកម្ពុជាក្រោមនោះ គេតែងតែសុំការអនុញ្ញាតពីលោកប្រធានគណៈប្រតិភូ ដើម្បីចុះទៅខេត្តផ្សេងៗទៀត ដែលមានខ្មែរក្រោមរស់នៅ និងគណៈប្រតិភូគ្មានគម្រោងចុះទៅនោះ ។

ដូចជាថ្ងៃមួយ ពេលដែលគណៈប្រតិភូ បញ្ចប់ទស្សនកិច្ចចំនួនមួយថ្ងៃ នៅក្នុងខេត្តឃ្លាំង (វត្តផ្នោរកា ឃុំកំពង់ធំ ស្រុកខ្សាច់) ហើយត្រូវវិលត្រឡប់មកសម្រាកនៅទីក្រុងព្រៃនគរចំនួន ២ ថ្ងៃ ដើម្បីជួបសម្ដែងការគួរសម និង សំណេះសំណាលជាមួយនឹងថ្នាក់ដឹកនាំនៃមន្ត្រី អ្នកមុខ អ្នកការ នៃយួនខាងត្បូងនោះ វិបុល និង សំណាង គេបានសុំការអនុញ្ញាតពីលោក ដាញ់ សាង ដើម្បីទៅទស្សនាខេត្តពលលាវ ដែលមានចម្ងាយប្រមាណជាជាង ៥០ គីឡូម៉ែត្រ ពីទីប្រជុំជនខេត្តឃ្លាំង ។ ក្រោយពីបានទទួលការអនុញ្ញាតពីលោកប្រធានរួចហើយ ពួកគេក៏បានធ្វើដំណើរតាមរថយន្តឈ្នួលមួយគ្រឿង និង បានទៅដល់ទីប្រជុំជនខេត្តពលលាវ វេលា ម៉ោង១១ថ្ងៃត្រង់ ។ វិបុល និង សំណាង បានចូលទៅក្នុងហាងលក់បាយមួយ ដើម្បីទទួលទានអាហារថ្ងៃត្រង់ មុននឹងបន្តដំណើរទៅកាន់ភូមិសាស្ត្រមួយចំនួនទៀត ដែលជាទីកន្លែងយួនបានសម្លាប់ខ្មែរក្រោម កាលពីឆ្នាំ១៩៤៥ ដូចជា ៖ កោះម្ហូត្ត ស្រែអំបិល (យ៉ាវ៉ាយ) និង ហោផុងជាដើម ដែលស្ថិតនៅប្រហែលជា ៥០ គីឡូម៉ែត្រ ពីទីប្រជុំជនខេត្តពលលាវ និង បន្តធ្វើដំណើរទៅកាន់ ខេត្តទឹកខ្មៅ (អាន ស្វៀន) ទៀត ។

ពេលចូលទៅក្នុងហាងបាយ ដោយវិបុលគឺជាខ្មែរដែលមានដើមកំណើតនៅកម្ពុជា ដូច្នេះគេមិនចេះភាសាវៀតណាមទេ ។

ឯចំណែកកម្លោះ សំណាង វិញថ្វីបើគេមានដើមកំណើតនៅកម្ពុជាក្រោមមែន ប៉ុន្តែដោយគេចាកចេញពីស្រុកកំណើត មករស់នៅក្នុងប្រទេសកម្ពុជាតាំងពីក្មេងនោះ ដូច្នេះភាសាវៀតណាមរបស់អ្នកកម្លោះយើងក៏មិនពូកែដែរ ។ *(នៅមានត)*




ប្អូនៗ យុវវ័យជាទីមេត្រី ក្នុងយុគសម័យកុំព្យូទ័រដែលមានសកម្មភាពដ៏មមាញឹកនេះ ពិតជាប្អូនៗ ពុំមានឱកាស យប់ឡើង ស្តាប់យាយតានិទានរឿងព្រេងខ្មែរ ឬទេវកថា ឬស្តាប់ព្រះធម៌ទេសនា ដែលមានអត្ថន័យបង្កប់នូវគតិបណ្ឌិតនៃប្រជាជាតិខ្មែរដ៏តូចច្រឡឹងរបស់យើងនៅជ្រួយអាស៊ីអាគ្នេយ៍នេះ និងបណ្តែតអារម្មណ៍ទៅក្នុងពិភពអរូបីជាប្រយោជន៍ បំផ្លេចនូវទុក្ខសោកបច្ចុប្បន្ន ដែលបង្កឡើងដោយជនបរទេសឈ្លានពានទឹកដីបានមួយខណៈ ហើយបង្កើតឡើងនៅលំនឹងចិត្តសាជាថ្មីដើម្បីបន្តការតស៊ូដ៏យូរអង្វែង និងពពេញទៅដោយកិត្តិយសជាតិរបស់យើង ។ ដោយយល់ដូច្នេះ អ្នកនិពន្ធព្រឹត្តិបត្រ **កម្ពុជាក្រោម** យើងខ្ញុំមានកិត្តិយសចុះផ្សាយនូវសេចក្តីសង្ខេបនៃរឿងបញ្ញាសជាតក ជារៀងរាល់លេខ សម្រាប់ជាចំណីអារម្មក្នុងពិភពអេឡិចត្រូនិចផង និងដើម្បីចម្រើនផ្នែកពុទ្ធកវិជ្ជាជូនយុវវ័យយើងដែលកំពុងសិក្សាស្រាវជ្រាវផង ។

# រឿងព្រះសមុទ្ទឃោស

ជាស្នាដៃនិពន្ធរបស់លោក **ញ៉ុក ថែម**

បោះពុម្ពលើកទី ១ នៅភ្នំពេញ ឆ្នាំ ១៩៥៩

**អតីតេ** ក្នុងកាលកន្លងមក យូរអង្វែងហើយ **ភរ** មានរឿងដំណាលថា មានព្រះមហាក្សត្រមួយអង្គ ព្រះនាមវិន្ទុទត្ត គ្រងរាជ្យនៅក្រុងព្រហ្មបុរី ដែនកាសី ។ មានព្រះមហេសី ព្រះនាមទេវធីតា មានព្រះរាជបុត្រមួយអង្គ ព្រះនាមសមុទ្ទឃោសកុមារ ។ តមក ព្រះរាជកុមារបានអភិសេកនឹងព្រះនាងវិន្ទុមតី រាជបុត្រនៃព្រះបាទ សិរិសីហនរគុត្ត នៅក្រុងរម្មបុរី ។

ថ្ងៃមួយព្រះរាជកុមារស្តេចទៅប្រពាតឧទ្យាន ជួនជាមានវិជ្ជាធរ ២ នាក់ ច្បាំងដណ្តើមភរិយាគ្នា នាកណ្តាលអាកាស ។ វិជ្ជាធរមួយបរាជ័យ ធ្លាក់ចុះមកកណ្តាលឧទ្យាននោះ សឹងមានរបួសសព្វរាងកាយ ។ ព្រះរាជកុមារទ្រង់ទតឃើញដូច្នោះ មានព្រះទ័យមេត្តា ទ្រង់បង្គាប់ឲ្យគ្រូពេទ្យនាំខ្លួនទៅរក្សាព្យាបាលត្រាតែសះជាដូចប្រក្រតី ។ វិជ្ជាធរនោះរលឹកនឹកដល់គុណទ្រង់ ទើបថ្វាយព្រះខ័នវិសេសដល់ទ្រង់ដើម្បីតបគុណ ។

ព្រះខ័ននោះមានឫទ្ធិ អាចនាំហោះហើរលើអាកាសបាន ទើបព្រះសមុទ្ទឃោសកុមារ និងព្រះជាយា ស្តេចហោះធ្យានទៅទ្រង់ក្រសាលព្រៃភ្នំហេមពាន្ត រហូតដល់ភ្នំកៃលាស អស់ថិរវេលាជាច្រើនខែ ។

លុះនាំមហេសីត្រឡប់មកនគរវិញ ស្តេចបានចូលទៅសម្រាកព្រះអង្គក្នុងល្អាងភ្នំមួយ នាព្រៃហេមពាន្ត ។ គ្រានោះមានវិជ្ជាធរមួយបានឃើញក្សត្រាក្សត្រីផ្ទំលក់ ក៏ចូលទៅលបលួចយកព្រះខ័នវិសេសនោះបាត់ទៅ ។ ក្សត្រទាំង ២ តើនឡើងរកព្រះខ័នមិនឃើញ ក៏ទ្រង់កន្សែងសោកមហិមា បណ្តើរគ្នារហូតដល់មាត់សមុទ្រមួយ ហើយនាំគ្នាតោងគល់រកា ១ ប្រុងហែលឆ្លងទៅត្រើយខាងនាយ ។ មិនយូរប៉ុន្មាន មានខ្យល់ព្យុះធំបោកបក់ក្សត្រទាំង ២ ឲ្យព្រាត់ប្រាសពីគ្នាទៅទៀត ។ ព្រះនាងវិន្ទុមតី ត្រូវរលកបោកបន្សាត់ទៅដល់ត្រើយសមុទ្រមួយអន្លើ ព្រះនាងសោកសង្រេងរកព្រះស្វាមីពុំឃើញ ហើយទើបចេញដំណើរតទៅទៀត ដរាបដល់ទៅនគរមទ្ទរដ្ឋ ព្រះនាងបានស្នាក់នៅនឹងជួនបាសម្នាក់ ហើយព្រះនាងប្រគល់ព្រះទម្រង់មួយវង់ឲ្យជួនបាសយកទៅចំណាយបានប្រាក់មាសមកហើយ បានជួលជាងឲ្យសង់សាងសាលាទាន ផ្គត់ផ្គង់អាហារភោជនដល់ស្មូមយាចកអ្នកដំណើរទេសទាំងឡាយ បានជួលជាងគំនូរឲ្យគូររឿងរ៉ាវដែលជាជីវប្រវត្តិព្រះនាង និងព្រះសមុទ្ទឃោសជាព្រះស្វាមីសព្វគ្រប់ ។

ឯព្រះសមុទ្ទឃោស បានត្រូវខ្យល់សមុទ្របក់ផាត់ទៅក្នុងសមុទ្រជ្រៅទៅ ប្រួនជានាងមណីមេខលាទេពតារក្សាសមុទ្រ

បានជួយស្រង់ទ្រង់ដាក់ដល់ត្រើយ ។ ព្រះឥន្ទ្រាធិរាជទ្រង់ជ្រាបថា ព្រះខ័នរបស់ព្រះអង្គមានវិជ្ជាធរមួយលួចយកទៅ ទើបទ្រង់បង្គាប់បង្ខំឲ្យវិជ្ជាធរនោះយកមកថ្វាយព្រះសមុទ្ទឃោសវិញ ។ ព្រះសមុទ្ទឃោសទ្រង់បានហោះផ្សានតាមអាកាសវិថី ហើយបានចុះកណ្ដាលក្រុងមទ្ទរដ្ឋ ដើម្បីស្វែងរកព្រះក្រយាស្ងោយ ដោយទ្រង់អត់អាហារមកយូរថ្ងៃហើយ ។

ទ្រង់បានដំណឹងថា នៅស្រុកនោះ មានស្រីម្នាក់មានចិត្តសប្បុរសបានសង់សាលាទានមួយសម្រាប់អ្នកដំណើរ ព្រមទាំងបានផ្គត់ផ្គង់អាហារភោជនដាក់ជាទានដល់ស្មូម និងអ្នកដំណើរផង ។ ទ្រង់បានយាងទៅកាន់សាលាទានរបស់ព្រះនាងវិន្ទុមតី ហើយនៅទីបំផុត ទ្រង់បានជួបព្រះមហេសីជាទីស្នេហា ក្រោយដែលបានធ្វើអំណោយទានដល់ស្មូមយាចក និងសមណព្រាហ្មណ៍ទាំងឡាយ រួចទ្រង់នាំព្រះមហេសីហោះផ្សានតាមផ្លូវអាកាសរហូតដល់ក្រុងរម្មបុរី បុះក្នុងព្រះរាជឧទ្យាន ។ ឯនាយឧយ្យានបាលបានក្រឡេកឃើញព្រះអង្គ ស្គាល់ជាក់ជាអង្គព្រះសមុទ្ទឃោសហើយ ក៏រត់ទៅក្រាបបង្គំទូលព្រះបាទសីហនរគុត្តជាព្រះវរបិតា ៗ មានព្រះរាជហឫទ័យត្រេកអរណាស់ ហើយទ្រង់បានធ្វើពិធីរាជាភិសេកព្រះរាជបុត្រា បុត្រីឲ្យឡើងគ្រងរាជ្យជាតំណាងតាងព្រះអង្គ រួចហើយស្ដេចលាចេញទៅទ្រង់ព្រះផ្នួសជាឥសី ។ ឯព្រះបាទវិន្ទុទត្ត នៃក្រុងព្រហ្មបុរីទ្រង់បានត្រាស់ហៅព្រះសមុទ្ទឃោស ជាព្រះរាជបុត្រមកដល់ហើយ ទ្រង់បានប្រគល់រាជសម្បត្តិហើយ ស្ដេចចេញទៅទ្រង់ព្រះផ្នួសជាឥសីដែរ ។

ឯព្រះបាទសមុទ្ទឃោស ទ្រង់បានសង់សាលាទាននៅនគរទាំង ២ សម្រាប់ស្មូមយាចក និងអ្នកកំសត់ទុគ៌ត ហើយទ្រង់បានទូន្មានមហាជនឲ្យរក្សាសីល ប្រព្រឹត្តតែការកុសលសុចរិក ។ អ្នកនគរទាំង ២ ឋិតនៅក្នុងឱវាទរបស់ទ្រង់ ក៏បានក្ដីសុខក្សេមក្សាន្តរៀងរាបដរាបរៀងទៅ ៕




*សាលាឆទាន សម្រាប់ជនភៀសខ្លួនខ្មែរកម្ពុជាក្រោមនៅព្រះរាជាណាចក្រកម្ពុជា ប្រារព្ធពិធីបុណ្យតាមប្រពៃណីសាសនា ស្ថិតនៅភូមិសាមគ្គី ខ័ណ្ឌឫស្សីកែវ រាជធានីភ្នំពេញ*